**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងមុខងារសាធារណៈ**

# សាររំលែកមរណទុក្ខ

## ជូនចំពោះ
## លោកជំទាវ នុត សុតី ព្រមទាំងក្រុមគ្រួសារ

**លោកជំទាវ និងក្រុមគ្រួសារ** ជាទីស្រឡាញ់រាប់អាន!

ខ្ញុំ និងថ្នាក់ដឹកនាំ ព្រមទាំងមន្ត្រីរាជការទាំងអស់នៃក្រសួងមុខងារសាធារណៈ មានសេចក្ដីក្រៀមក្រំ និងសោកស្ដាយជាពន់ពេក ដោយបានទទួលដំណឹងថា **ឯកឧត្ដម នុត ណារ៉ាង** អតីតរដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ បានទទួលមរណភាពកាលពីថ្ងៃពុធ ៨រោច ខែទុតិយាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី៩ ខែសីហា ឆ្នាំ២០២៣ វេលាម៉ោង ២១:០០នាទី ក្នុងជន្មាយុ ៨៧ឆ្នាំ ដោយរោគាពាធ។

ក្នុងបរិយាកាសប្រកបដោយក្ដីរំជួលចិត្ត និងសមានទុក្ខដ៏ក្រៀមក្រំបំផុតនេះ ខ្ញុំ និងថ្នាក់ដឹកនាំ ព្រមទាំងមន្ត្រីរាជការទាំងអស់នៃក្រសួងមុខងារសាធារណៈ សូមចូលរួមសម្ដែងនូវមរណទុក្ខដ៏ក្រៀមក្រំ និងសោកស្ដាយជាទីបំផុតជាមួយ **លោកជំទាវ នុត សុតី ព្រមទាំងក្រុមគ្រួសារ** ចំពោះការបាត់បង់ដ៏ធំធេងដែលមិនអាចរកអ្វីមកប្រៀបបានមួយនេះ។

ការបាត់បង់ **ឯកឧត្ដម នុត ណារ៉ាង** គឺជាការបាត់បង់នូវវៃស្សរជន និងធនធានមនុស្សមួយរូប ដែលតែងតែបានពុះពារលះបង់អស់កម្លាំងកាយចិត្ត ធនធានប្រាជ្ញាស្មារតី ក្នុងការបម្រើប្រទេសជាតិ រួមចំណែកជាមួយរាជរដ្ឋាភិបាលក្នុងការអភិវឌ្ឍជាតិមាតុភូមិនាពេលកន្លងមក។

ខ្ញុំសូមឧទ្ទិសបួងសួងជូនដួងវិញ្ញាណក្ខន្ធ **ឯកឧត្ដម នុត ណារ៉ាង** បានអញ្ជើញទៅកាន់សុគតិភព កុំបីឃ្លៀងឃ្លាតឡើយ។

សូម **លោកជំទាវ នុត សុតី ព្រមទាំងក្រុមគ្រួសារ** ទទួលនូវការរំលែកទុក្ខដ៏ក្រៀមក្រំពីយើងខ្ញុំ។

ថ្ងៃសៅរ៍ ១១ រោច ខែទុតិយាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ សីហា ឆ្នាំ២០២៣

**តំណាងថ្នាក់ដឹកនាំនិងមន្ត្រីរាជការនៃក្រសួងមុខងារសាធារណៈ**
**រដ្ឋមន្ត្រី**

ព្រុំ សុខា